**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈគ្រូពេទ្យកម្ពុជា**
**ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ**

លេខ ០៤៩/២២ ក.គ.ជ

ថ្ងៃ អង្គារ ១៣កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២២

# ប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ

## ជម្រាបមក

## ឯកឧត្តម/លោកប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យ រាជធានី-ខេត្ត

**កម្មវត្ថុ:** ការដាក់ពាក្យជាបេក្ខជនក្រុមប្រឹក្សាសម្រាប់អាណត្ត៦ឆ្នាំលើកទីបួន។
**យោង:** -ព្រះរាជក្រឹត្យលេខនស/រកត/០២០០/០៣៩ ចុះថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ
-បទបញ្ជាផ្ទៃក្នុងរបស់គណៈគ្រូពេទ្យកម្ពុជា។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិសូមជម្រាបមក ឯកឧត្តម/ លោកប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តទាំងអស់ជ្រាបថា ស្ថានភាពជំងឺ CoVid-19បានធ្វើឱ្យអាកខានដល់សន្និបាតរយៈពីរឆ្នាំលើកទីបីនៃអាណត្តិប្រាំមួយឆ្នាំលើកទីបីរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានីខេត្ត និងជាតិ។ ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិបានសម្រេចឱ្យចាប់ផ្តើមរៀបចំមហាសន្និបាតបូកសរុបការងារអាណត្តិ៦ឆ្នាំលើកទី៣ និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងជាតិសម្រាប់អាណត្តិ៦ឆ្នាំលើកទី៤ចាប់ពីខែមេសាឆ្នាំ ២០២២នេះទៅ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម/លោកប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យ រាជធានី-ខេត្តប្រជុំកំណត់ថ្ងៃប្រារព្ធមហាសន្និបាត ដើម្បីជូនដំណឹងឱ្យគ្រូពេទ្យមកចូលរួមកុះករគ្រប់គ្នាតាមការកំណត់របស់បទបញ្ជាផ្ទៃក្នុង ទន្ទឹមនឹងនេះ សូមជំរុញឱ្យមានការដាក់ពាក្យជាបេក្ខជនចំពោះគ្រូពេទ្យដែលមានលក្ខណសម្បត្តិល្អដូចមានចែងក្នុងនីតិវិធីនៃការបោះឆ្នោត ដើម្បីឱ្យគ្រូពេទ្យទាំងអស់ក្នុងមហាសន្និបាតបោះឆ្នោតជ្រើសរើស។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម/លោកប្រធានក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តទាំងអស់ពិចារណារៀបចំការងារខាងលើឱ្យមានប្រសិទ្ធភាព។

សូម**ឯកឧត្តម លោកប្រធាន** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

សាស្ត្រាចារ្យវេជ្ជ. **ធា គ្រួយ**

**ចម្លងជូន:**
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ